# ខ្លឹមសារជំនឿលើព្រះយេស៊ូវគ្រីស្ទ ក្នុង៦មេរៀន

## មេរៀនទី២ តើព្រះដែលប្រទានព្រះគម្ពីរមានលក្ខណៈសម្បត្តិអ្វីខ្លះ?

**លំនាំដើម**

ការរំលឹកពីមេរៀនទី១

ប្រភពនៃព្រះគម្ពីរ

អាយុនៃព្រះគម្ពីរបរិសុទ្ធ

ព្រះគម្ពីរជាការពិតសុទ្ធសាធ

គ្មានអ្វីៗផ្សេងទៀតសំខាន់ជាជាងព្រះគម្ពីរបរិសុទ្ធនោះទេ

ឥឡូវយើងនឹងអានខគម្ពីរមួយដែលប្រហែលជាខគម្ពីរដែលគេស្គាល់ច្រើនជាងគេ ត្បិតជាមិនទទួលជឿព្រះយេស៊ូវក៏ដោយ ភាគច្រើននៅតែស្គាល់ខគម្ពីរនេះ។ ខគម្ពីរនេះជាឃ្លាខ្លឹមសាល្អមួយ អំពីរជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ។

**យ៉ូហាន ៣:១៦**

**ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។**

ថ្ងៃនេះខ្ញុំយកចិត្តទុកដាក់នូវចំពោះពាក្យដំបូងក្នុងខគម្ពីរនេះ គឺ «**ដ្បិតព្រះ**»។

ក្នុងមេរៀនទី១យើងបានសិក្សារថា ព្រះរបស់គ្រីស្ទបរិស័ទគឺ ព្រះដែលបង្កើតផ្ទៃមេឃនិងផែនដី។ យើងបានមើលខគម្ពីរដើមដែលអានថា

**«កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី» លោកុប្បត្តិ ១:១**

យើងបានរៀនដែរថា ព្រះនោះជាព្រះអាទិករ ព្រះអាទិទេពដ៏ពិត។

# លក្ខណៈសម្បត្តិរបស់ព្រះ

បើសិនជាលោកអ្នកបើកព្រះគម្ពីរ ហើយអានចាប់ពីឃ្លានោះមក អ្នកនឹងឃើញថា ព្រះបានបង្កើតសាកលលោកនេះក្នុង៦ថ្ងៃ។ ព្រះមានតែព្រះបន្ទូលចេញ ហើយរបស់សព្វសារពើមានឡើង! ព្រះទ្រង់បានបង្កើតអ្វីៗទាំងអស់មាននៅលើមេឃ នៅលើផែនដី ទាំងផ្កាយ សូរិយា លោកខែ គ្រប់អំណាចខាងវិញ្ញាណ។ សត្វគ្រប់ប្រភេទ រុក្ខជាតិទាំងអស់ ច្បាប់ធម្មជាតិ សុទ្ធតែជារបស់ដែលព្រះអម្ចាស់បានបង្កើតមក។ ហើយនៅពេលដែលទ្រង់បង្កើតទាំងអស់រួច ព្រះទ្រង់

**«ឃើញថា ទាំងអស់ជាការល្អប្រពៃ»** លោកុប្បត្តិ ១:៣១

## តើយោងតាមគម្ពីរដំបូងនេះយើងឃើញថា ព្រះអង្គមានលក្ខណៈសម្បត្តិអ្វីខ្លះ?

ព្រះមានគ្រប់អំណាចព្រះចេស្តា

ទ្រង់ខ្ពង់ខ្ពស់ជាងអ្វីទាំងអស់

ព្រះជាប្រភពជីវិត

ទ្រង់ល្អបរិសុទ្ធ

ព្រះមានប្រាជ្ញាគ្រប់គ្រាន់ដើម្បីបង្កើតសាកលលោកនេះ ហើយបង្កើតវាល្អប្រពៃ គ្មានអ្វីមិនល្អ ឬអាក្រក់ទេ ទ្រង់ជ្រាបគ្រប់កិច្ចការទាំងអស់

ព្រះមានជីវិតតាំងពីអស់កល្ប គ្មានអ្នកណាបង្កើតទ្រង់ទេ

ប្រហែល៦៥០ឆ្នាំមុនព្រះគ្រិស្តសករាជ ព្រះអាទិករមានបន្ទូលតាមរយៈព្យាការីថា

**«ពួកអ្នកដែលរួចពីសាសន៍ដទៃអើយ ចូរប្រមូលគ្នាមក ហើយចូលឲ្យជិត**

**ពួកអ្នកដែលលើកយកដុំឈើធ្វើជារូបព្រះឆ្លាក់របស់គេ ហើយអធិស្ឋានដល់ព្រះដែលជួយសង្គ្រោះខ្លួនមិនបាន នោះជាអ្នកអាប់ឥតប្រាជ្ញាទេ។**

**ចូរថ្លែងប្រាប់ ហើយសម្ដែងហេតុចេញចុះ ត្រូវប្រឹក្សាគ្នា តើអ្នកណាបានប្រាប់ពីការនេះ**

**តាំងពីចាស់បុរាណមក? តើអ្នកណាបានថ្លែងទំនាយទុក តាំងពីយូរមកហើយ?**

**តើមិនមែនយើងជាយេហូវ៉ាទេឬ?**

**ក្រៅពីយើង គ្មានព្រះឯណាទៀត ដែលជាព្រះសុចរិត ហើយជាព្រះអង្គសង្គ្រោះទេ គ្មានណាមួយក្រៅពីយើងឡើយ។ មនុស្សទាំងអស់នៅចុងផែនដីអើយ ចូរមើលមកយើង ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតយើងនេះជាព្រះ ឥតមានព្រះណាទៀតឡើយ។»**

**អេសាយ ៤៥:២-០២២**

គ្មានអ្នកណា ឬព្រះណាដែលមានសិទ្ធិអំណាចនិយាយបែបនេះទេ លើកលែងតែព្រះដែលបង្កើតរបស់សព្វសារពើមក។

មួយទៀត ព្រះមានសិទ្ធិអំណាចលើមនុស្សលោកទាំងអស់។ សូមស្តាប់ខគម្ពីរដែលពណ៌នាអំពីនៅពេលដែលព្រះបង្កើតមនុស្ស

ព្រះមានព្រះបន្ទូលថា៖ «ចូរយើងបង្កើតមនុស្ស ឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង ហើយចូរឲ្យគេមានអំណាចលើត្រីសមុទ្រ លើសត្វហើរលើអាកាស លើសត្វជើងបួន និងលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារ ដែលវារនៅលើផែនដីផង»។

ព្រះបានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង

ព្រះអង្គបានបង្កើតគេ ជាប្រុសជាស្រី។

ព្រះបានប្រទានពរគេ គឺព្រះអង្គមានព្រះបន្ទូលថា៖ «ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតផងទាំងឡាយដែលកម្រើកនៅលើផែនដីផង»។

ព្រះទ្រង់មានព្រះបន្ទូលថា៖ «មើល៍! យើងឲ្យគ្រប់ទាំងតិណជាតិដែលមានគ្រាប់ពូជដុះនៅលើផែនដី និងគ្រប់ទាំងរុក្ខជាតិទាំងឡាយដែលមានផ្លែ ហើយមានគ្រាប់បន្តពូជ ទុកជាអាហារដល់អ្នក។

យើងក៏ឲ្យគ្រប់ទាំងតិណជាតិខ្ចីៗ ទុកជាអាហារដល់អស់ទាំងសត្វនៅផែនដី សត្វហើរលើអាកាស និងសត្វលូនវារនៅដី ដែលមានជីវិតទាំងប៉ុន្មានដែរ» នោះក៏កើតមានដូច្នោះមែន។

ព្រះទ្រង់ទតអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមក ឃើញថាល្អប្រពៃណាស់ នោះក៏មានល្ងាច មានព្រឹក ជាថ្ងៃទីប្រាំមួយ។ លោកុប្បត្តិ ១:២៦-៣១

ដូច្នេះយើងឃើញលក្ខណៈសម្បត្តិរបស់ព្រះថែមទៀត គឺ

ព្រះជាម្ចាស់របស់មនុស្ស ទ្រង់បង្កើតមនិស្សដើម្បីស្គាល់ព្រះ ធ្វើជាដំណាងព្រះ ថ្វាយសិរីល្អដល់ព្រះ និងថែទាំផែនដីដែលទ្រង់បង្កើត។ មានុស្សមានការទទួលខុសត្រូវនូវចំពោះព្រះអង្គ។

ទ្រង់មានទំនាក់ទំនងជាមួយមនុស្ស

ព្រះជាព្រះនៃសេចក្ដីស្រឡាញ់ និងសប្បុរស ព្រោះទ្រង់បានរៀបចំទាំងអស់សម្រាប់មនុស្ស

# ការបញ្ចប់

មនុស្សភាគច្រើនមិនស្គាល់ព្រះជាម្ចាស់ទេ គាត់មិនដឹងគុណព្រះ មិនគោរពទ្រង់ ហើយគោរពថ្វាយបង្គំព្រះដែលមនុស្សបង្កើតទៅវិញ។ ភាគច្រើនពឹងលើប្រាជ្ញាខ្លួន ឬប្រាជ្ញារបស់អ្នកដទ៉យទៀត សុកចិត្តកាន់ទំនាមទំលាប់របស់មនុស្ស ហើយមិនស្វែងរកសេចក្ដីពិត។

សូមនឹកចំពីព្រះបន្ទូលព្រះដែលយើងបានអានម្ដងហើយ

**«ក្រៅពីយើង គ្មានព្រះឯណាទៀត ដែលជាព្រះសុចរិត ហើយជាព្រះអង្គសង្គ្រោះទេ គ្មានណាមួយក្រៅពីយើងឡើយ។ មនុស្សទាំងអស់នៅចុងផែនដីអើយ ចូរមើលមកយើង ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតយើងនេះជាព្រះ ឥតមានព្រះណាទៀតឡើយ។»**